# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ០៤៩ សសរ.កសក

## សេចក្តីសម្រេច
## ស្តីពី
## ការកំណត់ថ្លៃឈ្នួលដែននេសាទសមុទ្រ

---

### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៦ ស្តីពី ការប្តូរឈ្មោះនាយកដ្ឋានជលផល ទៅជារដ្ឋបាលជលផល
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ១៩៨៩ ស្តីពីការជួលដែននេសាទទឹកសាប និងសមុទ្រឱ្យធ្វើអាជីវកម្ម
- តាមសំណើរបស់រដ្ឋបាលជលផលលេខ ០៧៧ ជផ. ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៧

## សម្រេច

**ប្រការ ១ :** ត្រូវបានកំណត់ថ្លៃឈ្នួលដែននេសាទសមុទ្រ តាមប្រភេទឧបករណ៍នេសាទសម្រាប់អនុវត្តក្នុងឆ្នាំ ២០០៧ និងឆ្នាំ ២០០៨ ដូចមានក្នុងតារាងខាងក្រោម :

| ល.រ | ប្រភេទឧបករណ៍ | ឯកត្តា | ថ្លៃឈ្នួលដែននេសាទ |
|---|---|---|---|
| ១ | អួនអួស | ១ សេះ | ២៧.០០០ ៛ ០០ |
| ២ | ឈ្នាងអួសត្រំក្រឡាហ្វូល | ១ សេះ | ២៧.០០០ ៛ ០០ |
| ៣ | អួនខ្វូវ | ១ ម | ៣.៥០០ ៛ ០០ |
| ៤ | អួនទិត និង អួនផ្សេងៗ | ១ ម | ៤.៦០០ ៛ ០០ |
| ៥ | មងបង្គា | ១ ម | ២០០ ៛ ០០ |
| ៦ | មងត្រីក្បក | ១ ម | ១០០ ៛ ០០ |
| ៧ | មងត្រីផ្សេងៗ | ១ ម | ២០០ ៛ ០០ |
| ៨ | ប៉ុក | ១ គ្រឿង | ៨៦៧.០០០ ៛ ០០ |
| ៩ | សំណាញ់បណ្តោយលើសពី ៦ម | ១ វង់ | ៤.៦០០ ៛ ០០ |
| ១០ | មងក្តាម | ១ ម | ១០០ ៛ ០០ |
| ១១ | ឈ្នក់ក្តាម | ១ គ្រឿង | ៤០០ ៛ ០០ |
| ១២ | លបក្តាម | ១ គ្រឿង | ៥០០ ៛ ០០ |
| ១៣ | លបមឹក | ១ គ្រឿង | ១.៥០០ ៛ ០០ |
| ១៤ | លបត្រី | ១ គ្រឿង | ៥.០០០ ៛ ០០ |
| ១៥ | ផ្ទងផាងបង្គា | ១ មាត់ | ៥០.០០០ ៛ ០០ |
| ១៦ | ផ្ទងផាងតី | ១ មាត់ | ២៥.០០០ ៛ ០០ |
| ១៧ | ឈ្នាងចាប់ក្រែងឈាម | ១ គ្រឿង | ១.២០០ ៛ ០០ |
| ១៨ | សន្ទូចលើសពី ១០ ផ្លែ | ១ ផ្លែ | ៤០០ ៛ ០០ |

**ប្រការ ២** : សេចក្តីសម្រេចណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣** : អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធានរដ្ឋបាលជលផល និង ប្រធានការិ.ជលផលគ្រប់ខេត្ត ក្រុងដែលមានដែននេសាទសមុទ្រ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារៈកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៧

រដ្ឋមន្ត្រី

ឆ័ន្ទ សារុន

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់សាលាខេត្ត ក្រុងពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ